ខ និងលក្ខខណ្ឌ

# បានទាំងអ្នក បានទាំងខ្ញុំ

## Personal Customer Referral Program

1. សុពលភាពនៃការផ្តល់ជូនពិសេស៖ ថ្ងៃទី០១ ខែកក្កដា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ឬរហូតអស់ថវិកាដែលបានកំណត់។
2. ប្រភេទគណនី៖ គណនីសន្សំ Goal ឬ គណនី Premier ឬ Premier Savings Plus ហើយការផ្តល់ជូនពិសេសនេះមិនត្រូវបានអនុវត្តសម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់ឡើយ។
3. ការផ្តល់ជូនពិសេសនេះ សម្រាប់អតិថិជនសេវាធនាគារបុគ្គលទាំងអស់ (ទាំងអតិថិជនចាស់ និងអតិថិជនថ្មី) ដែលបានណែនាំ និងបើកគណនី ក្នុងកំឡុងពេលផ្តល់ជូនពិសេសនេះ។
4. អតិថិជនចាស់នៃសេវាធនាគារបុគ្គលទាំងអស់ ដែលណែនាំមិត្តភក្តិ និងក្រុមគ្រួសារ ត្រូវបានចាត់ទុកថាជា“អ្នកណែនាំ”។ អតិថិជនថ្មី ដែលបើកគណនីដូចបានរៀបរាប់ខាងលើ ក្នុងកំឡុងពេលផ្តល់ជូនពិសេសនេះ ត្រូវបានចាត់ទុកថាជា “អ្នកទទួលការណែនាំ”។
5. ចំនួនទឹកប្រាក់ត្រលប់មកវិញនឹងត្រូវបញ្ចូលទៅក្នុងគណនីរបស់អ្នកណែនាំ និងអ្នកទទួលការណែនាំ នៅក្នុងរយៈពេល ៦០ថ្ងៃ (យ៉ាងយូរ) ប្រសិនបើអ្នកទទួលការណែនាំបំពេញតាមលក្ខខណ្ឌខាងក្រោម៖

| ប្រភេទគណនី | អតិថិជនចាស់ (អ្នកណែនាំ) | អតិថិជនថ្មី (អ្នកទទួលការណែនាំ) |
|---|---|---|
| គណនីសន្សំ Goal | • ទទួលបានប្រាក់ត្រលប់មកវិញ ចំនួន ៥ដុល្លារ នៅពេលណែនាំ អតិថិជនថ្មីបើកគណនី និងរក្សា សមតុល្យមធ្យមប្រចាំថ្ងៃ (average daily balance) សម្រាប់ខែដំបូង ចំនួន ១០០ដុល្លារ | • ទទួលបានប្រាក់ត្រលប់មកវិញចំនួន ៥ដុល្លារ នៅពេល បើកគណនី និងរក្សាសមតុល្យមធ្យមប្រចាំថ្ងៃ (average daily balance)សម្រាប់ខែដំបូង៥០០ ដុល្លារ<br>• ឥតគិតកម្រៃសេវាទទួលប្រាក់ពីក្រៅប្រទេស ពេញមួយឆ្នាំ<br>• កម្រៃជើងសារ 0.13% (អប្បបរមា 20 ដុល្លារ អាមេរិក) និងថ្លៃសេវាខ្សែកាប 15 ដុល្លារអាមេរិក សម្រាប់សេវាផ្ទេរប្រាក់ទៅក្រៅប្រទេសពេញ មួយឆ្នាំ<br>• ឥតគិតកម្រៃសេវាប្រចាំឆ្នាំ បណ្ណឥណទានវីសា Classic ឬ Platinum សម្រាប់ឆ្នាំដំបូង<br>• អតិថិជននឹងទទួលបានកាដូផ្សេងៗទៀត |

| | | |
|---|---|---|
| គណនី Premier ឬ Premier Savings Plus | • ទទួលបានប្រាក់ត្រលប់មកវិញ ចំនួន ៥០ដុល្លារ នៅពេលណែនាំ អតិថិជនថ្មីបើកគណនី និង រក្សា សមតុល្យមធ្យមប្រចាំថ្ងៃ (average daily balance) សម្រាប់ខែដំបូង ចំនួន ២៥.០០០ដុល្លារ | • ទទួលបានប្រាក់ត្រលប់មកវិញចំនួន ២៥ដុល្លារ នៅពេល បើកគណនី និង រក្សាសមតុល្យមធ្យម ប្រចាំថ្ងៃ (average daily balance) សម្រាប់ខែដំបូងចំនួន ២៥.០០០ដុល្លារ<br>• ឥតគិតកម្រៃសេវាសមតុល្យក្រោមអប្បបរមា សម្រាប់គណនី Premier ឬ Premier Saving Plus ប្រសិនបើកបន្ថែមគណនីប្រាក់បញ្ញើមានកាលកំណត់ចំនួន ១០០.០០០ ដុល្លារ ជាមួយអាត្រាការប្រាក់ដែលបានផ្តល់ជូនសម្រាប់គណនីប្រាក់បញ្ញើមានកាលកំណត់<br>• ឥតគិតកម្រៃសេវាទទួលប្រាក់ពីក្រៅប្រទេស ពេញមួយឆ្នាំ<br>• កម្រៃជើងសារ 0.13% (អប្បបរមា 20 ដុល្លារអាមេរិក) និងថ្លៃសេវាខ្សែកាប 15 ដុល្លារអាមេរិក សម្រាប់សេវាផ្ទេរប្រាក់ទៅក្រៅប្រទេសពេញមួយឆ្នាំ<br>• ឥតគិតកម្រៃសេវាប្រចាំឆ្នាំ បណ្ណឥណទានវីសា Classic ឬ Platinum សម្រាប់ឆ្នាំដំបូង<br>• អតិថិជននឹងទទួលបានកាដូផ្សេងៗទៀត |

6. រាល់គណនីថ្មីដែលបើកត្រឹមថ្ងៃទី១៥ ក្នុងខែនីមួយៗ នឹងត្រូវ ធ្វើការផ្ទៀងផ្ទាត់សម្រាប់លក្ខខណ្ឌទទួលបានការផ្តល់ជូនពិសេសនេះនៅក្នុងខែតែមួយ។ ។ ក្រៅពីនេះ ការផ្ទៀងផ្ទាត់នឹងត្រូវធ្វើឡើងនៅខែបន្ទាប់។

7. អ្នកណែនាំ អាចទទួលបានទឹកប្រាក់ត្រលប់មកវិញច្រើនជាងមួយលើក ដោយគ្រាន់តែណែនាំអតិថិជនថ្មីបើកគណនី និងបំពេញតាមលក្ខខណ្ឌដែលបានកំណត់។ រីឯអ្នកទទួលការណែនាំ អាចទទួលបានទឹកប្រាក់ត្រលប់មកវិញ តែមួយលើកប៉ុណ្ណោះ។

8. ការផ្តល់ជូនពិសេសនេះ មិនអនុវត្តសម្រាប់បុគ្គលិក នោះទេ។

9. ការផ្តល់ជូនពិសេសនេះនឹងធ្វើឡើងតាមគោលការណ៍ “មកមុន បានមុន”។

10. បុគ្គលិករបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ នឹងមិនធ្វើការ ទាក់ទងទៅអ្នកណែនាំ ឬអ្នកទទួលការណែនាំ ពាក់ព័ន្ធនឹងទឹកប្រាក់ត្រលប់មកវិញ នោះទេ។

11. ខ និងលក្ខខណ្ឌពាក់ព័ន្ធនឹងកម្រៃសេវា និងអត្ថប្រយោជន៍ នៃគណនីនីមួយៗ នឹងត្រូវយកមកអនុវត្ត។

12. ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ រក្សាសិទ្ធិតាមឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការបញ្ចប់ ផ្លាស់ប្តូរ លុបចោល ឬបន្ថែមខ និងលក្ខខណ្ឌណាមួយ ដោយមិនជម្រាបជូនដំណឹងជាមុនឡើយ។

J Trust Royal Bank